**BMI0118**

# សម្ភាសន៍ជាមួយឈ្មោះ លុច ជួប អាយុ៥៥ ភេទប្រុស

## មុខងារខ្មែរក្រហមៈ ធ្វើឈ្លប

## ស្រុកកំណើតនៅភូមិតាភរ ឃុំតាភរ ស្រុកថ្មពួក ខេត្តបាត់ដំបង

## សព្វថ្ងៃរស់នៅភូមិបន្ទាយឆ្មារខាងលិច ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ឡុង ដានី

០០:៣៨:០០

២៦ទំព័រ

ដានី ៖ មុនដំបូងខ្ញុំសុំស្គាល់ឈ្មោះពូ ពូឈ្មោះពេញឈ្មោះអីដែរ?

ជួប ៖ ខ្ញុំឈ្មោះ លុច ជួប ។

ដានី ៖ ពូអាយុប៉ុន្មានហើយសព្វថ្ងៃ?

ជួប ៖ អាយុ៥៥ ។

ដានី ៖ ពូស្រុកកំណើតពូនៅភូមិឃុំអីដែរ ស្រុកកំណើត?

ជួប ៖ ស្រុកកំណើតនៅភូមិតាភរ ឃុំតាភរ ស្រុកស្វាយចេក ។

ដានី ៖ ហ្នឹងស្រុកស្វាយចេកតាំងពីជំនាន់ណាម៉ោ?

ជួប ៖ ជំនាន់សម័យយើងនេះឯង យើងបង្កើតខេត្តបន្ទាយមានជ័យនេះ បានកើតអាស្រុកស្វាយចេក ។

ដានី ៖ ខេត្តបន្ទាយមានជ័យ?

ជួប ៖ បាទ!ពីមុនខេត្តបាត់ដំបង ។

ដានី ៖ ចុះកាលពីសង្គមក្នុងស្រុកអីទេ?

ជួប ៖ ស្រុកថ្មពួក ។

ដានី ៖ ឃុំតាភរ ស្រុកថ្មពួក ខេត្តបាត់ដំបង?

ជួប ៖ បាទ!

ដានី ៖ ដល់ឥឡូវគេបង្កើតជាភូមិតាភរ ឃុំតាភរ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ?

ជួប ៖ បាទ!

ដានី ៖ សព្វថ្ងៃពូរស់នៅក្នុងភូមិ ឃុំអីដែរ?

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

ជួប ៖ ភូមិបន្ទាយឆ្មារខាងលិច ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។

ដានី ៖ ប្រពន្ធពូគាត់ឈ្មោះអីដែរ?

ជួប ៖ ឈ្មោះ អ៊ុច ដាម ។

ដានី ៖ គាត់អាយុប៉ុន្មានដែរ?

ជួប ៖ ៥៨ឆ្នាំ ។

ដានី ៖ គាត់បងពូ?

ជួប ៖ បាទ!បង ។

ដានី ៖ បាទ!ពូមានកូនចៅទាំងអស់ប៉ុន្មាននាក់ហើយ?

ជួប ៖ កូនមាន៤នាក់ ។

ដានី ៖ ៤នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ជួប ៖ ស្រី១នាក់ ប្រុស៣នាក់ ។

ដានី ៖ សព្វថ្ងៃពូប្រកបរបររកស៊ីធ្វើអីដែរ?

ជួប ៖ ធ្វើតែស្រែហ្នឹងឯង ។

ដានី ៖ ចុះអ៊ីឪពុកពូគាត់ឈ្មោះអីដែរ?

ជួប ៖ គាត់ឈ្មោះ លុច ជុំ ។

ដានី ៖ សព្វថ្ងៃគាត់នៅរស់ ឬក៏គាត់ស្លាប់ហើយ?

ជួប ៖ ស្លាប់ហើយ ។

ដានី ៖ គាត់ស្លាប់តាំងពីឆ្នាំណា?

ជួប ៖ ចាំមិនបានទេ ប្រហែល៣ឆ្នាំហើយគាត់ស្លាប់ ។

ដានី ៖ គាត់ឈឺជំងឺចាស់?

ជួប ៖ ចាស់ ជរា ។

ដានី ៖ ម្តាយគាត់ឈ្មោះអី?

ជួប ៖ មីន វ៉ាង ។

ដានី ៖ មីន វ៉ាង គាត់ទឹមស្លាប់ដែរ?

ជួប ៖ ទឹមស្លាប់ ។

ដានី ៖ ពូមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

ជួប ៖ បងប្អូនបង្កើត៧នាក់ ។

ដានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ជួប ៖ ស្រី២នាក់ ប្រុស៥នាក់ ។

ដានី ៖ ពូជាកូនទីប៉ុន្មាន?

ជួប ៖ ខ្ញុំកូនទី៥ អ៊ុះកូនទី៣ ។

ដានី ៖ ពូកាលពីក្មេងៗ រៀនសូត្រអីដល់ណា?

ជួប ៖ រៀនដល់ថ្នាក់ទី៨ពីដើម ។

ដានី ៖ ម៉េចបានរៀនបានត្រឹមថ្នាក់ទី៨?

ជួប ៖ វាអស់ប្រាក់រៀន ។

ដានី ៖ បាទ!កាលរៀនហ្នឹងរៀននៅសាលាណា នៅភូមិ?

ជួប ៖ នៅតាភរហ្នឹង ពួកម៉ាកខ្ញុំមួយគេធ្វើការធំៗណាស់សព្វថ្ងៃ ។

ដានី ៖ ចុះបន្ទាប់ពីឈប់រៀនហើយធ្វើអីទៀតទៅ?

ជួប ៖ ម៉ោនៅនេះ ។

ដានី ៖ ដល់ពេលឈប់រៀនហើយ ម៉ោនៅបន្ទាយឆ្មារ?

ជួប ៖ បាទ!ម៉ោនៅឆ្នាំ៦៩ម៉ោនៅនេះ ។

ដានី ៖ ទាំងគ្រួសារទាំងអស់?

ជួប ៖ ទាំងអស់ ។

ដានី ៖ ១៩៦៩ផ្លាស់ម៉ោទាំងគ្រួសារម៉ង?

ជួប ៖ បាទ!

ដានី ៖ ម៉ោនៅបន្ទាយឆ្មារហ្នឹងទាំងអស់គ្នា?

ជួប ៖ បាទ!ម៉ោទាំងអស់ ។

ដានី ៖ ផ្លាស់ម៉ោនៅហ្នឹងហើយយ៉ាងម៉េចទៀតទៅ ធ្វើការងារអីទៅ?

ជួប ៖ ធ្វើស្រែចំការហ្នឹង ។

ដានី ៖ ធ្វើស្រែនៅជាមួយឪពុកម្ដាយ?

ជួប ៖ បាទ!

ដានី ៖ អញ្ចឹងបន្ទាប់ពីហ្នឹងម៉ោ ធ្វើស្រែរហូតដល់ពេលណាទៅ?

ជួប ៖ ដល់នេះបែកបាក់គ្នាសម័យ កាលសម័យខ្មែរក្រហម ។

ដានី ៖ សម័យខែរក្រហមឆ្នាំណាបែកបាក់? រដ្ឋប្រហារ?

ជួប ៖ 	រដ្ឋប្រហារនៅជាមួយគ្នា ។

ដានី ៖ 	រដ្ឋប្រហារឆ្នាំ៧០ហ្នឹងនៅជាមួយគ្នានៅឡើយ?

ជួប ៖ 	បាទ!នៅជាមួយគ្នា ។

ដានី ៖ 	នៅរហូតដល់ណា?

ជួប ៖ 	នៅរហូតដល់សម័យ៧៥ សម័យ៧៥ហ្នឹងមិនដែលបានបែកបាក់ទៅណាទេ ប៉ុននៅជាមួយគ្នាដែរ ប៉ុនមិនដែលបាននៅជាមួយគ្នាទេ បែកបាក់ពីនេះមួយ ទៅនោះមួយ ។

ដានី ៖ 	ចុះកាលឆ្នាំ១៩៧៥ហ្នឹង កាលហ្នឹងពូធ្វើអីខ្លះទៅ ហើយកាលហ្នឹងគ្រួសារគេឲ្យធ្វើអី ខ្លះ?

ជួប ៖ 	គ្រួសារគេឲ្យធ្វើការទៅចល័តទៅអីនោះឯង ។

ដានី ៖ 	បាទ! ចុះពូកាលហ្នឹងគេចាត់ឲ្យធ្វើអី?

ជួប ៖ 	ធ្វើចល័តដូចតែគ្នាហ្នឹង មិនដែលបាននៅផ្ទះទេ ។

ដានី ៖ 	ធ្វើចល័តហេ៎?

ជួប ៖ 	ធ្វើចល័ត ។

ដានី ៖ 	ធ្វើចល័តនៅណា?

ជួប ៖ 	ធ្វើចល័ត អូ! ពេញតែភូមិនេះឯង ខុបនៅតាមក្បាលដីរ ថ្នល់ដាច់ ។

ដានី ៖ 	ក្បាលដីរ ថ្នល់ដាច់ធ្វើចល័ត?

ជួប ៖ 	បាទ!

ដានី ៖ 	ចុះអ៊ើ!ឪពុកម្តាយ?

ជួប ៖ 	ឪពុកម្តាយអីវ៉ាន់ហ្នឹងគ្នាម៉ាគនរម៉ាដូរអាហួសសំរេងនេះ គេយកឲ្យទៅនៅចាំចំការ ចំការដំឡូង ។

ដានី ៖ 	ឪពុកម្តាយធ្វើចំការដំឡូង?

ជួប ៖ 	បាទ!គាត់ចាស់ៗហើយគេឲ្យគាត់ទៅនៅចាំចំការ ។

ដានី ៖ 	ចុះបងប្អូន?

ជួប ៖ 	បងប្អូនអាខ្លះគេទៅនៅត្រពាំងថ្ម ស្រុកបិទអាងនោះៗឯង ម្តុំនោះព្រៃចង្ហារ ។

ដានី ៖ 	ទៅធ្វើអីនៅហ្នឹង?

ជួប ៖ 	ទៅធ្វើចល័ត កងចល័តបិទទំនប់អាងត្រពាំងថ្មហ្នឹង កាលនោះព្រៃចង្ហារៗក៏ចល័តដូចគ្នា ដាំកប្បាស ។

ដានី ៖ 	ធ្វើអាងត្រពាំងថ្ម?

ជួប ៖ បាទ!

ដានី ៖ ព្រៃចន្លោះដាំកប្បាស?

ជួប ៖ បាទ!

ដានី ៖ ចុះពួកឯចល័តធ្វើស្អីខ្លះ?

ជួប ៖ កងចល័តគេឲ្យស្ទូងដក ។

ដានី ៖ គេឲ្យស្ទូងដក?

ជួប ៖ ហ្នឹងហើយ បិទភ្លឺ មើលថែស្រូវធ្វើស្រូវ គ្រប់សព្វបែបយ៉ាង បិទទំនប់ត្រូវបិទទំនប់ ជីកប្រឡាយត្រូវជីកប្រឡាយ ។

ដានី ៖ គ្នាច្រើន?

ជួប ៖ ច្រើនណាស់រាប់រយនាក់ ។

ដានី ៖ រាប់រយនាក់?

ជួប ៖ បាទ!រាប់រយនាក់មួយកងធំ ។

ដានី ៖ ពូធ្វើប្រធានកងធំ?

ជួប ៖ ទេ!អត់ធ្វើទេ ។

ដានី ៖ ពីណាគេធ្វើប្រធានកង?

ជួប ៖ បើធ្វើប្រធានក្រុមគេធ្វើខ្លះ ។

ដានី ៖ ធ្វើប្រធានក្រុមធ្វើខ្លះ?

ជួប ៖ បាទ!

ដានី ៖ ប្រធានក្រុមមួយមានគ្នាប៉ុន្មាននាក់?

ជួប ៖ ប្រធានក្រុម មួយក្រុម១០នាក់ ។

ដានី ៖ មួយក្រុម១០នាក់?

ជួប ៖ ហ្នឹងហើយ ។

ដានី ៖ ប្រធានក្រុម ដូចយើងធ្វើប្រធានក្រុម យើងយ៉ាងម៉េច យើងគ្រាន់តែនាំកម្លាំងធ្វើការទេ?

ជួប ៖ ហ្នឹងហើយ នាំកម្លាំងធ្វើការ ។

ដានី ៖ មានអីទៀត?

ជួប ៖ មានស្អីមានតែប៉ុណ្ណឹង នាំគេធ្វើការហ្នឹង ។

ដានី ៖ ធ្វើកងចល័តរហូតដល់ពេលណាទៅ?

ដួប ៖ ធ្វើកងចល័តរហូតដល់ឃុំនចូលវៀ បានបែកគ្នាមួយសារទៀត ។

ដានី ៖ បាទ!ពូមានធ្លាប់ធ្វើកងឈ្លបទេ?

ដួប ៖ ទេ!មិនដែលធ្វើទេ ។

ដានី ៖ កងចល័តហ្នឹងធ្វើការងារយ៉ាងម៉េចទៅ ដូចថាយើងពេលនៅៗធ្វើម៉ាកន្លែងៗ ?

ដួប ៖ ធ្វើម៉ាកន្លែងដូចថាគេឲ្យយើងដូចថាស្ទូង ស្ទូងនៅម៉ាកម្លាំងដែលយើងក្តាប់ទៅចុះស្ទូងទៅ ម៉ាក្រុមម៉ាកងធំក៏មានអនុប្រធានក្រុមមួយចុះទៅស្ទូង បើស្ទូងស្រូវវស្សាមួយក្រុម ម៉ាហិចតា ស្ទូងគ្នា១០នាក់ ។

ដានី ៖ បាទ!

ដួប ៖ គ្នា១០នាក់ហ្នឹងគេឲ្យស្ទូងម៉ាហិចតា ធ្វើម៉េចឲ្យរួចម៉ាហិចតាគ្នា១០នាក់ ។

ដានី ៖ ពីណាគេជាអ្នកប្រាប់ឲ្យស្ទូង?

ដួប ៖ កាលនោះដឹងស្រាប់ហើយ អង្គការគេ ។

ដានី ៖ ប៉ុន្តែអ្នកប្រាប់យើងផ្ទាល់ អ្នកប្រធាន?

ដួប ៖ ប្រធានកងធំ ។

ដានី ៖ ប្រធានកងចល័តធំហ្នឹង?

ដួប ៖ បាទ!

ដានី ៖ ពីណាគេជាប្រធានកងចល័តធំ?

ដួប ៖ រត់បែកបាក់គ្នាបាត់ហើយ ។

ដានី ៖ អ្នកភូមិយើងដែរ?

ដួប ៖ ទេ!រត់បែកបាក់គ្នា បាត់ហើយ ។

ដានី ៖ បាទ!ប៉ុន្តែពួកគាត់អ្នកភូមិយើងដែរ?

ដួប ៖ ទេ!មិនមែនទេ ។

ដានី ៖ ម៉ោពីណាម៉ោ?

ដួប ៖ សុទ្ធតែពួកមក អានៅនេះអ៊ីវាមានហើយ ប៉ុនកាលសម័យកាលហ្នឹងអាតាមភូមិវា ក្តាប់គ្នាឯងមិនសូវអីទេ ។

ដានី ៖ បាទ!

ដួប ៖ មិនសូវគានតឹងទេ ។

ដានី ៖ បាទ!

ជួប ៖ ដល់ទៅយកអានិរតីមកដាក់បានធូន់ ។

ដានី ៖ អញ្ចឹង?

ជួប ៖ បាទ!

ដានី ៖ ពួកនិរតីកាច?

ជួប ៖ កាច ។

ដានី ៖ ពួកនិរតីធ្វើម៉េចទៅ?

ជួប ៖ ហ៊ឺ! ត្រូវសម្លាប់ៗពួកហ្នឹង ។

ដានី ៖ កាលជំនាន់ពួកនិរតីអត់ទាន់ម៉ោ អត់ទាន់មានអ្នកសម្លាប់ទេ?

ជួប ៖ ទេ! សម្លាប់ដែរ ប៉ុន្តែវាមិនសូវប្រើអំពើហិង្សាខ្លាំង វាប្រើកម្លាំងខ្លាំង វាប្រើទៅតាមវាឲ្យស៊ីឲ្យអីគ្រប់ៗ ហើយវាសណ្ដំដាង ហើយឲ្យធ្វើការវាមិនសូវជាបង្ខំអ្នកណាទេ ដល់ធ្លាក់ចូលអាពួកនិរតីម៉ោនេះបានធូន់ ។

ដានី ៖ បាទ! ចុះពូអត់ធ្លាប់ធ្វើឈ្លបអេស៎?

ជួប ៖ ធ្លាប់កាលដែលនៅគោកនេះ ។

ដានី ៖ អ្ហូ! កាលណា នៅគោកណា?

ជួប ៖ នៅគោកសំរោង ។

ដានី ៖ កាលហ្នឹងពូផ្លាស់ពីភូមិទៅនៅគោកសំរោង?

ជួប ៖ ហ្នឹងហើយ នៅតាជីហ្នឹង នៅស្រុកតាជី គេឲ្យធ្វើនោះហើយ ។

ដានី ៖ គេអត់ឲ្យយើងធ្វើនៅភូមិកំណើតយើងទេ?

ជួប ៖ ទេ! អត់ឲ្យធ្វើទេ ។

ដានី ៖ កាលហ្នឹងឪពុកម្ដាយពូនៅនេះ?

ជួប ៖ គាត់នៅនោះឯង ។

ដានី ៖ នៅអី នៅគោកសំរោងហ្នឹង?

ជួប ៖ នៅគោកសំរោងហ្នឹង ។

ដានី ៖ គោកសំរោងហ្នឹង នៅឃុំអីគេកាលហ្នឹង?

ជួប ៖ ឃុំនេះហើយ ។

ដានី ៖ ឃុំគោកសំរោង ភូមិបន្ទាយឆ្មារដែរ?

ជួប ៖ បាទ!

ដានី ៖ ទៅនៅហ្នឹង ពូធ្វើឈ្លបពីឆ្នាំណាដល់ឆ្នាំណាដែរ?

ជួប ៖ ធ្វើពី ។

ដានី ៖ បែកៗ ចូលសម័យប៉ុល ពត ឆ្នាំ៧៥?

ជួប ៖ ចុះឆ្នាំ៧៥ បានធ្វើ ។

ដានី ៖ ធ្វើចុងឆ្នាំ៧៥ដល់ឆ្នាំណា?

ជួប ៖ អ៊ើ!ដល់ឆ្នាំ៧៦ ចុងឆ្នាំ៧៦ឈប់ ។

ដានី ៖ ម៉េចបានឈប់?

ជួប ៖ គេឲ្យយើងមានគ្រួសារមានអីគេឲ្យចល័ត ក៏ចល័តទៅនោះឯង ។

ដានី ៖ អូ!ពេលយើងមិនទាន់មានគ្រួសារគេឲ្យយើងធ្វើឈ្លប?

ជួប ៖ បាទ!ហ្នឹងហើយ ។

ដានី ៖ ធ្វើឈ្លបពីណាអ្នកចាត់តាំងឲ្យធ្វើ?

ជួប ៖ គណៈភូមិ ឃុំនោះឯងគេចាត់តាំង ។

ដានី ៖ គណៈឃុំសង្កាត់បន្ទាយឆ្មារហ្នឹង?

ជួប ៖ បាទ!

ដានី ៖ ពីណាគេ ឈ្មោះអីកាលហ្នឹង?

ជួប ៖ ឈ្មោះ តា យឹប ។

ដានី ៖ គាត់ជាអ្នកស្រុកភូមិយើងដែរ?

ជួប ៖ ទេ!គាត់ម៉ោពីនោះឯង ។

ដានី ៖ មកពីណា?

ជួប ៖ មកពីខាង ប៉ុនអាមនុស្សដូចជាភូមិយើងវាទំនាក់ទំនងនិយាយឆាប់ត្រូវគ្នា ។

ដានី ៖ គាត់មកពីខាងណា?

ជួប ៖ មិនដឹងម៉ោពីទេកាលហ្នឹង មិនដឹងស្រុកគាត់នៅណាទេ ។

ដានី ៖ ចុះម៉េចគាត់ស្គាល់ពូ គាត់ឲ្យពូធ្វើឈ្លប?

ជួប ៖ ចុះគាត់ម៉ោដល់ប្រធានភូមិគេរើស មានអ្នកនៅក្នុងភូមិនេះគេរើស ស្គាល់អ្នកណាគេរើស ។

ដានី ៖ ប្រធានភូមិពីណាគេកាលហ្នឹង?

ជួប ៖ កាលហ្នឹងប្រធានភូមិលោក តាភឹលសព្វថ្ងៃហ្នឹង ។

ដានី ៖ លោកតាភឹល?

ជួប ៖ បាទ!

ដានី ៖ លោក តាភឹលវត្តណា?

ជួប ៖ វត្តនេះ ។

ដានី ៖ វត្តបន្ទាយឆ្មារហ្នឹង?

ជួប ៖ បាទ!គាត់បួសហើយសព្វថ្ងៃ ។

ដានី ៖ អញ្ចឹងគាត់ចាត់ពូឲ្យធ្វើឈ្លបហើយប៉ុន្មាននាក់ធ្វើឈ្លប?

ជួប ៖ ច្រើនមួយក្រុម ប៉ុនសព្វថ្ងៃអាខ្លះក៏នៅ អាខ្លះក៏ស្លាប់បាត់ហើយ ។

ដានី ៖ អ្ហូ!ឈ្លបមានតួនាទីអីខ្លះទៅឈ្លប?

ជួប ៖ គេឲ្យដើរមើលយាម ។

ដានី ៖ គេឲ្យដើរ ដើរយាម?

ជួប ៖ ហ្នឹងហើយ យាម ។

ដានី ៖ យាមម៉េច?

ជួប ៖ យាមយប់ យាមអីហ្នឹង ។

ដានី ៖ យាមយប់ យាមតាមភូមិ?

ជួប ៖ ហ្នឹងហើយ យាមតមភូមិ ។

ដានី ៖ ដូចថាគេមានគោលការណ៍ថាយើងត្រូវ ប្រជាជន កាលហ្នឹងនៅក្នុងភូមិមានប្រជាជនថ្មី ប្រជាជនអ្នកជម្លៀស១៧មេសាម៉ោដែរ?

ជួប ៖ ទេ!អត់មានទេ ។

ដានី ៖ អត់ទេ?

ជួប ៖ នៅក្នុងភូមិនេះអត់មានទេ ។

ដានី ៖ អត់មានអ្នក១៧មេសា?

ជួប ៖ អត់មានទេ!

ដានី ៖ សុទ្ធតែប្រជាជនមូលដ្ឋាន?

ជួប ៖ បាទ!មូលដ្ឋានទាំងអស់ ។

ដានី ៖ ចុះគេប្រាប់យើងថាធ្វើម៉េចខ្លះ?

ជួប ៖ គេឲ្យធ្វើការ មើលខុសត្រូវអារឿងចុះចូលខ្មាំងអី ។

ដានី ៖ បាទ!

ជួប ៖ ស៊ីរូងផ្ទៃក្នុងដើរស៊ើបការស៊ើបអី ឲ្យយើងទៅពិបាកខំធ្វើណា បើដើរវិញដើរទៅណាដើរគេឲ្យដើរ ។

ដានី ៖ អញ្ចឹងគេប្រាប់យើងថាឲ្យម៉ោរកខ្មាំងស៊ីរូងផ្ទៃក្នុងអីអញ្ចឹង?

ជួប ៖ បាទ!

ដានី ៖ ចុះពូមានដែលរកឃើញទេ?

ជួប ៖ ហ៊ើ!មិនដែលរកឃើញទេ ។

ដានី ៖ អត់បានឃើញទេ?

ជួប ៖ បាទ!

ដានី ៖ អញ្ចឹងគេមិនថាឲ្យ ថាយើងធ្វើការអត់បាន?

ជួប ៖ គេថាឲ្យតែប៉ុណ្ណឹង ។

ដានី ៖ គេមានថាឲ្យ ឬស្តីឲ្យអត់?

ជួប ៖ ទេ!មិនថាទេ ។

ដានី ៖ កាលជំនាន់ពូមានដែលចាប់អ្នកណាដែលធ្វើខុសអីឬអត់?

ជួប ៖ អត់ដែលមានទេ ។

ដានី ៖ អត់ទេណ៎ុះ?

ជួប ៖ អត់ ។

ដានី ៖ ដល់ពេល ធ្វើការតែក្នុងភូមិគោកបន្ទាយហ្នឹងទេ?

ជួប ៖ ហ្នឹងហើយ ។

ដានី ៖ ដល់ពេលឆ្នាំ?

ជួប ៖ ដល់ពេលគេជម្លៀសពិនោះ ម៉ោនេះខ្ញុំធ្វើប្រធានក្រុម ។

ដានី ៖ គេជម្លៀសពីណាម៉ោ?

ជួប ៖ ពីនោះហ្នឹងហើយ ។

ដានី ៖ ពីណា?

ជួប ៖ ពីតាបេកម៉ោ ។

ដានី ៖ ភូមិតាបេក?

ជួប ៖ ភូមិតាចេក ។

ដានី ៖ កាលហ្នឹងធ្វើឈ្លប នៅភូមិតាចេក?

ជួប ៖ នៅភូមិតាចេក ។

ដានី ៖ មិនមែនអ្នកគោកបន្ទាយទេ?

ជួប ៖ ទេ!ដល់មកដល់នេះគេឲ្យធ្វើប្រធានក្រុម ។

ដានី ៖ អ៊ូ!អញ្ចឹងដំបូងកាលពូផ្លាស់ម៉ោពីកាលឆ្នាំ៦៩ហ្នឹង ម៉ោនៅភូមិបន្ទាយឆ្មារខាង លិចហ្នឹង?

ជួប ៖ អេស៎!ម៉ោពីភូមិនោះ នោះអាភូមិនោះ ។

ដានី ៖ ភូមិអីគេហ្នឹង?

ជួប ៖ ភូមិខាងជើង ។

ដានី ៖ ភូមិបន្ទាយឆ្មារខាងជើង?

ជួប ៖ បាទ!

ដានី ៖ បាទ!ដល់ពេលសម័យ៣ឆ្នាំ គេជម្លៀសពូទៅនៅ?

ជួប ៖ ទេ!អាសម័យអា៣ឆ្នាំនោះហើយគេជម្លៀសមកនេះ ដល់ម៉ែឪដូចថាដូចប្រាប់អញ្ចឹង នៅគោកសំរោង ។

ដានី ៖ នៅគោកសំរោង?

ជួប ៖ បាទ!

ដានី ៖ អញ្ចឹងភូមិដែលពូផ្លាស់មកពីតាករ ម៉ោនៅដំបូងម៉ោនៅណា?

ជួប ៖ នៅដៃ ។

ដានី ៖ មកនៅតាដៃ?

ជួប ៖ នោះហើយ ។

ដានី ៖ ដំបូងមកនៅតាដៃ អញ្ចឹងមានមកនៅបន្ទាយនេះទេ ?

ជួប ៖ ហ្នឹងហើយមិនមកនៅនេះទេ ដល់សម័យ៣ឆ្នាំបានមកនៅនេះ ។

ដានី ៖ ម៉េចបានម៉ោនៅនេះវិញ?

ជួប ៖ គេដកឲ្យមកនៅនេះ ។

ដានី ៖ ពីណាអ្នកដក?

ជួប ៖ ឃុំគេ គេប្រមូលកម្លាំងឲ្យមកនៅមួយម្តុំ ។

ដានី ៖ ប៉ុន្តែឪពុកម្តាយឲ្យនៅនោះដដែល នៅតាចេកដដែល?

ជួប ៈ អត់ទេ!គាត់នៅគោកសំរោងគេឲ្យចាំចំការ ។

ដានី ៈ អ្ហូ!អញ្ចឹងដល់ពេលសម័យ៣ឆ្នាំគាត់ផ្លាស់ពីតាចេក មកនៅគោកសំរោង?

ជួប ៈ ហ្នឹងហើយ មកនៅគោកសំរោង ។

ដានី ៈ ពូធ្វើឈ្លបនៅតាដែ?

ជួប ៈ បាទ!ធ្វើឈ្លបនៅតាដែ ឥឡូវផ្លាស់ពីនោះម៉ោ ម៉ោនៅនេះខ្ញុំធ្វើប្រធានក្រុមហើយ ។

ដានី ៈ ម៉ោកន្លែងភូមិបន្ទាយឆ្មារខាងជើងនេះពូធ្វើប្រធានក្រុម?

ជួប ៈ ហ្នឹងហើយ ។

ដានី ៈ ផ្លាស់ពីឈ្លបមកធ្វើប្រធានក្រុម ម៉េចបានផ្លាស់ពីឈ្លបមកធ្វើប្រធានក្រុម?

ជួប ៈ ចុះបើគេដកចេញពីឈ្លបហើយ គេឲ្យធ្វើប្រធានក្រុម ធ្វើប្រធានក្រុមទៅ ។

ដានី ៈ ប្រធានក្រុមមានគ្នាប៉ុន្មាននាក់?

ជួប ៈ ៣០គ្រួសារ ក្រុមគ្រួសារហ្នឹង ។

ដានី ៈ សុទ្ធតែប្រជាជនមូលដ្ឋានដែរ?

ជួប ៈ ប្រជាជនមូលដ្ឋាន ។

ដានី ៈ ចុះកាលហ្នឹងពូធ្វើឈ្លបមានធ្លាប់ឃើញគេចាប់មនុស្សដែរឬអត់?

ជួប ៈ ក្រោយៗម៉ោឃើញគេចាប់ដែរ ។

ដានី ៈ ប៉ុន្តែកាលដំបូងពូ?

ជួប ៈ ដំបូងខ្ញុំមិនទាន់ចាប់ទេ ។

ដានី ៈ អត់ទាន់ចាប់ទេ?

ជួប ៈ បាទ!ទោះបីជាចាប់ក៏ខ្ញុំមិនដែលបានទៅចាប់គេ ។

ដានី ៈ ប៉ុន្តែគេមានដែរ?

ជួប ៈ មាន ។

ដានី ៈ ប៉ុន្តែពូ មិនដែលចុះចាប់?

ជួប ៈ មិនដែលចុះចាប់ទេ ការងាររវាខុសគ្នា ។

ដានី ៈ គេចាប់ គេច្រើនតែចាប់ពួកមានទោសយ៉ាងម៉េចបានគេចាប់?

ជួប ៈ មិនដឹង!គេចាក់ចុចគ្នាវា ។

ដានី ៈ គេចាក់ចុច?

ជួប ៈ ហ្នឹងហើយ ។

ដានី ៖ ចាក់ចុចម៉េច?

ជួប ៖ វាវយាវយៃ ចេះចុះ គ្នាវារាយការណ៍តែពាក្យខុសប៉ុណ្ណឹង ។

ដានី ៖ រាយការណ៍តែពាក្យខុសរឿងអី?

ជួប ៖ អាខ្លះថាដើរលួចដើរអី បើវាឃ្លានវា វាដើរលួចខ្លះទៅ ។

ដានី ៖ តែដើរលួចគេចាប់ហើយណ៎ុះ?

ជួប ៖ ចាប់ហើយ ។

ដានី ៖ គេចាប់ គេយកធ្វើអី គេគ្រាន់តែចាប់ហើយប្រលែងវិញ ឬក៏ចាប់ហើយ គេយកទៅសម្លាប់?

ជួប ៖ អ្ហូ!តែចាប់ហើយគេគ្មានលែងទេ ។

ដានី ៖ អត់លែងទេណ៎ុះ?

ជួប ៖ ហ្នឹងហើយ ដាក់គុកថ្មពួក ។

ដានី ៖ ពូដែលឃើញទេ?

ជួប ៖ ឃើញដែរ គុកថ្មពួក ។

ដានី ៖ នៅណា គុកថ្មពួក?

ជួប ៖ គុកថ្មពួក ។

ដានី ៖ គេដាក់គុកថ្មពួក?

ជួប ៖ ហ្នឹងហើយ ។

ដានី ៖ គុកថ្មពួកនៅកន្លែងណា?

ជួប ៖ នោះអាសាលាកាលិស ។

ដានី ៖ អាសាលាកាលិសថ្មពួកហ្នឹង?

ជួប ៖ ហ្នឹងហើយ ។

ដានី ៖ ចាប់ពីនេះយកទៅដាក់នៅនោះ?

ជួប ៖ ហ្នឹងហើយ ។

ដានី ៖ អ្ហូ!ឆ្ងាយចឹងអីគេដឹកអីយកទៅ?

ជួប ៖ គេដឹកកាលណារទេះសេះ កាលណាមានឡានគេមកយក ។

ដានី ៖ ចុះពូដែលទៅដល់គុក?

ជួប ៖ ទៅរត់ គេប្រើឲ្យទៅយកឯកសារអីៗកិច្ចការរបស់គេហ្នឹង ។

ដានី ៖ អ៊ូ!ឯកសារអីៗកិច្ចការរបស់គេ?

ជួប ៖ ហ្នឹងហើយ មិនហានមើលទេក្នុងសំបុត្រហ្នឹង គេហុចម៉ោថាឲ្យយកទៅឲ្យចៅហ្វាយស្រុក យកទៅឲ្យគេចៅហ្វាយស្រុកទៅ ។

ដានី ៖ ពីណាហ្នឹង?

ជួប ៖ ឃុំ ។

ដានី ៖ ពីតាឃីបហ្នឹង?

ជួប ៖ អេស៎ឃុំមួយទៀត តាឃីបស្លាប់ហើយកាលនោះ ម៉ាជំនាន់ៗ ។

ដានី ៖ ឃុំមួយទៀតពីណាគេ?

ជួប ៖ មួយទៀតឈ្មោះតាសុាំៗ ។

ដានី ៖ អញ្ចឹងតាឃីបគាត់ស្លាប់ដោយសារអី?

ជួប ៖ គេចាប់យកទៅ ។

ដានី ៖ គេចាប់យកទៅសម្លាប់?

ជួប ៖ យកទៅសម្លាប់ ។

ដានី ៖ ដល់អញ្ចឹងគេឲ្យតាសុាំ ឲ្យឈ្លបយកសំបុត្រទៅ សំបុត្រហ្នឹងមិនដឹងសំបុត្រអីទេ ទៅដល់កន្លែងគណៈស្រុកថ្មពួក គណៈស្រុកឈ្មោះអីកាលហ្នឹង?

ជួប ៖ គណៈស្រុកឈ្មោះ តារិទ្ធិ ។

ដានី ៖ ឈ្មោះ តារិទ្ធិ?

ជួប ៖ តារិទ្ធិហ្នឹងឯង ។

ដានី ៖ រិទ្ធិក្រោយទេ ចុះមុនរិទ្ធិនោះ តាឆាតអីដែលស្គាល់គាត់ឬអត់?

ជួប ៖ អ៊ូ!តាឆាត តាឆាតហ្នឹងឯង តាឆាត ។

ដានី ៖ ដល់ពេលក្រោយម៉ោបានឈ្មោះ រិទ្ធិ?

ជួប ៖ ហ្នឹងហើយ ក្រោយតាឆាតឈ្មោះរិទ្ធិ ។

ដានី ៖ មានពីណា ច្រើននាក់?

ជួប ៖ អាក្រោយ អ្នកនិរតីនេះខ្ញុំអត់ស្គាល់ទេ មិនដឹងឈ្មោះអី ។

ដានី ៖ បាទ!ប៉ុន្តែកាលដែលពូយកសំបុត្រទៅឲ្យៗពីណាគេ?

ជួប ៖ ឲ្យនៅកន្លែងគេធ្វើការនៅស្រុកនោះ ។

ដានី ៖ ប៉ុន្តែឲ្យពីណា គណៈស្រុកឈ្មោះអីកាលហ្នឹង?

ជួប ៖ គណៈស្រុកកាលហ្នឹង តារិទ្ធិហ្នឹងឯង ស្គាល់ច្បាស់តែតារិទ្ធិមុនគេ ។

ដានី ៖ តារិទ្ធិហ្នឹងឃើញគាត់ ធ្លាប់ស្គាល់គាត់ដែរ?

ជួប ៖ ស្គាល់!តាហួតមួយកាលនេះគាត់ធ្លាប់ដើរជាមួយគ្នា ។

ដានី ៖ បាទ!អញ្ចឹងពូធ្វើឈ្លបរហូតដល់ចុងឆ្នាំ៧៦?

ជួប ៖ ៧៦ ។

ដានី ៖ បាទ!ដល់ពេលបន្ទាប់ម៉ោធ្វើប្រធានក្រុមម្តង?

ជួប ៖ គេឲ្យធ្វើប្រធាន ។

ដានី ៖ ពូដើររត់សំបុត្រ?

ជួប ៖ បាទ!

ដានី ៖ អញ្ចឹងនៅស្រុកយើងនេះ អត់ដែលមានអ្នកទិន្នាការគេចាប់ទេ គេចាប់អ្នកដែល?

ជួប ៖ ចាប់ ។

ដានី ៖ ចាប់ដែរ?

ជួប ៖ ចាប់ពួកទាហាន ។

ដានី ៖ ចាប់ពួកទាហាន?

ជួប ៖ ហ្នឹងហើយនៅសម័យអាសម័យនិរតីចូលម៉ោហ្នឹង នោះគេរត់គេចាប់ អាកាលពីលើកមុនគ្មានទេ គ្មានចាប់ទេ ។

ដានី ៖ អ្ហូ!កាលពីឆ្នាំណាពួកនិរតីចូលម៉ោ?

ជួប ៖ ឆ្នាំ៧៧នេះឯង ។

ដានី ៖ អ្ហូ!៧៧នេះទេ?

ជួប ៖ ហ្នឹងហើយ ។

ដានី ៖ កាលហ្នឹងដល់ពួកនិរតីចូលម៉ោ ពូនៅធ្វើប្រធានក្រុមដែរ?

ជួប ៖ នៅធ្វើប្រធានក្រុម ។

ដានី ៖ អ្ហូ!កាលហ្នឹងពូ ដូចពូចយើងនៅធ្វើឈ្លបធ្វើអី យើងធ្វើការងារអី យើងបានហូបចុកអីច្រើនជាងអ្នកប្រជាជនឬក៏?

ជួប ៖ ប៉ះថ្ងៃណាដែលគេនាំទៅរៀនទៅសូត្រទៅ បានស៊ីសំណំគ្រាន់បើដែរ ហើយគេប្រធានក្រុមហ្នឹងទៅរៀននៅថ្នពួកស៊ី គេដាំបាយដាំអីឲ្យស៊ី ។

ដានី ៖ បានម្ហូបឆ្ងាញ់បាយឆ្ងាញ់?

ជួប :	បាយក៏ទទេឆ្ងាញ់ អត់មានម្ហូបណាទេ ឲ្យតែមានបាយពេញពោះ ។

ដានី :	បាទ!ចុះបើនៅភូមិ?

ជួប :	នៅភូមិដូចតែគ្នាហ្នឹងឯង របបវាដូចតែគ្នា មួយចានដូចតែគ្នា ។

ដានី :	យើងហូបនៅរោងបាយដែរ?

ជួប :	ហ្នឹងហើយ គេវាល់ឲ្យមានតែមួយចានៗ ទៅស៊ីក្បត់ណាកើត ។

ដានី :	អ្ហូ!អត់កើតទេ?

ជួប :	យើងម៉ោនៅដូចយើងធ្វើស្រែអញ្ចឹង មួយក្រុមៗ យើងទៅ ចុះទៅធ្វើស្រែទៅ គេយកបាយម៉ោចែកគ្នាមួយចានៗ យើងស៊ីត្រង់ហ្នឹង ។

ដានី :	បាទ!ក្រែងលោយើងមានកន្លែង កន្លែងយើងធ្វើការមានម្ហូបផ្សេង កន្លែងប្រជាជនមានម្ហូបផ្សេងអីទេ?

ជួប :	អត់ទេ ។

ដានី :	ខស្សាហ៍ទៅប្រជុំដែរអញ្ចឹង?

ជួប :	គេច្រើនប្រើខេសៗហ្នឹង ។

ដានី :	ប្រជុំគេដាក់ផែនការដូចម្ដេចខ្លះ?

ជួប :	ភ្លេចអស់ហើយ គ្មានស្អីមានតែនិយាយតែរឿងបង្កបង្កើនផលហ្នឹង បន្ទំឲ្យសកម្មប្រយុទ្ធអីហ្នឹង ។

ដានី :	ចុះអត់មាននិយាយរឿងអី ដូចថាធ្វើយ៉ាងម៉េចៗទេ?

ជួប :	អត់មានអីទេ គេគ្រាន់តែប្រាប់ អារឿងខ្មាំងស៊ីរូងស៊ីក្នុងណាទេ រឿងច្រើនណាស់ ។

ដានី :	អ្ហូ!ខ្មាំងស៊ីរូងផ្ទៃក្នុង?

ជួប :	បាទ!

ដានី :	ដល់ពេលពួកនិរតីម៉ោយ៉ាងម៉េច គេចាប់ៗម៉េច?

ជួប :	គេចាប់អាអ្នកមុនយកទៅសម្លាប់ចោលអស់ ។

ដានី :	គេចាប់អាអ្នកមុនម៉េច?

ជួប :	គេចាប់ចៅហ្វាយស្រុកៗ គេចាប់បន្តគ្នាហ្នឹង ។

ដានី :	អ្ហូ!គេចាប់បន្តគ្នាដែរ?

ជួប :	ហ្នឹងហើយ ។

ដានី :	ចាប់អ្នកធ្វើការមុន ដល់អ្នកពួកនិរតីម៉ោចាប់អ្នកហ្នឹងទៅ?

ជួប ៖ ហ្នឹងហើយ ។

ដានី ៖ ចុះដូចជីទាន់ពូ កាលពូធ្វើការគណៈឃុំ ខាងឈ្លបអីគេមានចាប់បន្តអញ្ចឹងឬអត់?

ជួប ៖ ចាប់ ពួកខ្ញុំហ្នឹងគេចាប់យកទៅម្ដង តែវាសំណាងណាស់បានវាមិនងាប់ ។

ដានី ៖ ពូ?

ជួប ៖ បាទ!

ដានី ៖ យ៉ាងម៉េចទៅពូអាចរៀបរាប់?

ជួប ៖ នោះគេចាប់ឈ្លបអីហ្នឹងមកចាប់ពូ ។

ដានី ៖ អត់ដឹងរឿងអីទេ?

ជួប ៖ អត់ ។

ដានី ៖ ពូអត់ដឹងដែរ?

ជួប ៖ ពួកអ្នកបាតសោមអ្នកអីចាប់អស់ ។

ដានី ៖ អ្នកណា? អ្នកបាតសោម?

ជួប ៖ ឥឡូវគេចាប់អស់ហើយអ្នកបាតសោម ។

ដានី ៖ អ្នកបាតសោម?

ជួប ៖ បាទ!

ដានី ៖ គាត់ធ្វើឈ្លបធ្វើអីដែរ?

ជួប ៖ បាទ!ធ្វើឈ្លប ។

ដានី ៖ គេចាប់?

ជួប ៖ គេចាប់ ។

ដានី ៖ គេចាប់យកទៅណាទៅ យកទៅថ្នួកទាំងអស់?

ជួប ៖ គ្មានយកទៅណាទេ មានតែយកទៅនោះឯង រត់ពោងព្រាត ។

ដានី ៖ បាទ!ខ្លះរត់ផុតទៅ?

ជួប ៖ រត់ទៅថៃផុត ។

ដានី ៖ ពូមានរត់ទៅថៃគេដែរឬអត់?

ជួប ៖ ទេ!ខ្ញុំអត់ទេ ។

ដានី ៖ អត់ទេ!នៅរហូតដល់យួនចូល?

ជួប ៖ យួនចូល ។

ដានី ៖ ពូធ្វើប្រធានក្រុមរហូតដល់យួនចូល?

ជួប ៖ ទេ! គេដក ។

ដានី ៖ ឆ្នាំណាគេដក?

ជួប ៖ គេដកចេញ ។

ដានី ៖ ម៉េចបានគេដកចេញ?

ជួប ៖ ព្រោះត្រូវធ្វើការកងចល័តទៀត ។

ដានី ៖ ត្រូវធ្វើការចល័តទៀត?

ជួប ៖ បាទ!

ដានី ៖ ឆ្នាំណាដែលគេដកពូចេញ?

ជួប ៖ មិនដឹងឆ្នាំណាទេ គិតមិនឃើញ ។

ដានី ៖ គិតមិនឃើញ! ជិតចប់យួនចូលឬនូវ?

ជួប ៖ ជិតចប់ហើយ គេដក ។

ដានី ៖ អញ្ចឹងពួកនិរតីម៉ោគេសម្លាប់ច្រើនអញ្ចឹង?

ជួប ៖ អ្ហូ! ច្រើនណាស់ងាប់អស់មិនតិចទេ ចុះកុហកគ្នាថាទៅរៀនទាំងគ្រួសារៗដែលមិនទៅ ។

ដានី ៖ ពីណាគេ ពួកណា?

ជួប ៖ ពួកនិរតីហ្នឹង ។

ដានី ៖ បាទ!

ជួប ៖ ដូចអាឈ្មោះទាហាន ចុះឈ្មោះអាណាមួយធ្វើទាហាន ទាំងប្តីទាំងប្រពន្ធទាំងកូនហៅម៉ោទៅថ្មពួក ។

ដានី ៖ ឆ្នាំណាហ្នឹង?

ជួប ៖ ភ្លេចឆ្នាំ អាហ្នឹងចប់ហើយ ។

ដានី ៖ ជិតចប់?

ជួប ៖ ហ្នឹងហើយ យូរអង្វែងហើយ ។

ដានី ៖ ចុះពួកនិរតីឈ្មោះអីខ្លះទៅ អ្នកដែលមកកាន់ប្រធាន?

ជួប ៖ ងាប់បាត់ហើយដឹង មួយងាប់នេះ ។

ដានី ៖ ឈ្មោះអីទៅ?

ជួប ៖ ឈ្មោះអាម៉ាក់ ។

ដានី ៖ ម៉ាក់ហ្នឹងប្រធានអី?

ជួប ៖ ប្រធានកងធំ ។

ដានី ៖ ប្រធានកងធំ?

ជួប ៖ ហ្នឹងហើយ ក្តាប់១០០គ្រួសារ ។

ដានី ៖ ក្តាប់១០០គ្រួសារ?

ជួប ៖ សម្រាប់ការដ្ឋានមួយៗ ។

ដានី ៖ ចុះប្រធានឃុំឈ្មោះ?

ជួប ៖ ប្រធានឃុំឈ្មោះ អាម៉ៃ ។

ដានី ៖ ម៉ៃហ្នឹងនៅណា?

ជួប ៖ មិនដឹងទេ!ងាប់ដឹង ។

ជិតខាង ៖ ងាប់បែកបាក់គ្នាអស់ ។

ដានី ៖ បាទ!ចុះពូរៀបការឆ្នាំណា?

ជួប ៖ ហ៊ឺ!ខ្ញុំរៀបការប្រពន្ធ២ ។

ដានី ៖ ប្រពន្ធ២នាក់?

ជួប ៖ ហ្នឹង អាមួយនេះ ។

ដានី ៖ ចុះមុន?

ជួប ៖ អាមុនងាប់

ដានី ៖ អាហ្នឹងរៀបការឆ្នាំណាហ្នឹង?

ជួប ៖ ឆ្នាំ៧៩ ។

ដានី ៖ ឆ្នាំ៧៩?

ជួប ៖ បាទ!

ដានី ៖ ចុះប្រពន្ធពូអ្នកស្រុកហ្នឹងដែរ?

ជួប ៖ អ្នកតាភរដូចគ្នា ។

ដានី ៖ អ្នកតាភរដូចគ្នា?

ជួប ៖ បាទ!

ដានី ៖ បាទ!ចុះកាលហ្នឹងពូមានកូនទេ?

ជួប ៖ កូនមួយ ពេលម៉ែវាឆ្លងទន្លេហ្នឹងងាប់ ។

ដានី ៖ អ៊ូ! ស្លាប់ពេលឆ្លងទន្លេ ទាំងកូនអីហ្នឹង?

ជួប ៖ កូននៅរស់ ។

ដានី ៖ កូននៅជាមួយពូដែរ?

ជួប ៖ បានប្រពន្ធបានអីអស់ហើយ នៅបែកគ្នា កូនវាមានសំណាងរស់ ។

ដានី ៖ បាទ! ដល់ពេល មីងរៀបការក្រោយទេ?

ជួប ៖ រៀបការក្រោយ សម័យយួន ។

ដានី ៖ សម័យយួនចូល?

ជួប ៖ បាទ!

ដានី ៖ ឆ្នាំ៨០ជាងហើយអញ្ចឹង?

ជួប ៖ បាទ!

ដានី ៖ អញ្ចឹងពូនៅក្នុងភូមិហ្នឹងរហូតដល់បែកយួនម៉ង អត់មានរត់ទៅណាទេ?

ជួប ៖ យួនចូលរត់ ។

ដានី ៖ យួនចូលរត់?

ជួប ៖ បាទ! រត់ទៅស្វាយ ។

ដានី ៖ អ៊ូ! ចុះម៉េចបានពូរត់ទៅស្វាយ?

ជួប ៖ រត់តាមបងខ្ញុំ បងស្រី ។

ដានី ៖ រត់ទៅនៅស្វាយអញ្ចឹង?

ជួប ៖ ថាទៅនៅស្វាយចេក តែមិនបាននៅស្វាយចេករត់ហួសទៅនៅស្វាយវិញ ។

ដានី ៖ ទៅនៅឆ្នាំណាបានត្រឡប់ម៉ោភូមិវិញ?

ជួប ៖ មិនយូរទេ នៅម៉ាប្រាំងហ្នឹង ។

ដានី ៖ នៅម៉ាប្រាំងទេ?

ជួប ៖ បាទ!

ដានី ៖ ចុះពូកាលហ្នឹងពូធ្វើប្រធានធ្វើអីអញ្ចឹងពូដឹងពីគោលនយោបាយ ម៉េចបានគេឲ្យយើងធ្វើស្រែច្រើនអញ្ចឹង ហើយគេអត់ឲ្យយើងហូបឆ្អែតអញ្ចឹង?

ជួប ៖ មិនអីទេ ។

ដានី ៖ អត់ដឹងទេពូ?

ជួប ៖ អត់ ។

ដានី :	កាលហ្នឹងយើងធ្វើស្រូវបានច្រើនដែលតើអី?

ជួប :	ស្រូវខ្វះអី តែគេមិនឲ្យស៊ីហ្នឹង ។

ដានី :	គេយកទៅណាទៅអញ្ចឹង?

ជួប :	មិនដឹង មិនដឹងគេដឹកទៅណាគេ ។

ដានី :	យើងដឹងតែពីធ្វើហើយស្រូវហ្នឹង?

ជួប :	ហ្នឹងហើយ ដឹងតែពីធ្វើប៉ុណ្ណោះហើយ ស្រូវធ្វើមួយឆ្នាំពាដង ។

ដានី :	នៅនេះគេឲ្យហូបបាយឬហូបបបរ?

ជួប :	បានតែខែនេះទេបាយនោះ ។

ដានី :	បាទ!

ជួប :	តែខែវស្សា កំពុងតែវ៉ៃខ្លាំង ស្រទាប់ខ្លាំងអ៊ូលេងតែបបរហ្នឹង ។

ដានី :	ចុះមានកម្លាំងដែលកាលហ្នឹង?

ជួប :	មិនមានឯណា បើខ្លាចងាប់ហ្នឹង មានកម្លាំងអី បេះតែទៅណ៎ ហើមពពីពពួត ។

ដានី :	ពួធ្លាប់ទៅប្រជុំទៅអី គេអត់មានប្រាប់ថាបង្កបង្កើនផល ម៉េចអត់ឲ្យយើងហូបចុក គ្រប់គ្រាន់អី?

ជួប :	គ្មានទេ!គ្មាននិយាយអញ្ចឹងៗទេ ឲ្យតែយើងខំ ។

ដានី :	យើងអត់ដែលប្រាប់គេថា ហូបតែបបរអី?

ជួប :	មានអ្នកណាពិបាកទៅហានប្រាប់វាណ៎ុះ ។

ដានី :	ចុះយើងធ្វើប្រធានដែរ យើងខ្លាចអី?

ជួប :	ហ៊ី!ងាប់អីឥឡូវប្រធានហ្នឹង លួមចៅហ្វាយស្រុកគេងាប់ ឯងធ្វើឡេឡឺ គេសួរបេះតែ បាទៗទៅណ៎ មិនឆ្អែតក៏ថាបាទ មិនដែលថាមិនឆ្អែតទេ ។

ដានី :	អញ្ចឹងកាលជំនាន់ហ្នឹងអត់បានទេអញ្ចឹង?

ជួប :	អត់បានទេ ។

ដានី :	ប្រធានក៏ដោយអីក៏ដោយ?

ជួប :	អ៊ូ!មិនថាលោកឪណាទេ ។

ដានី :	ចុះកន្លែងហ្នឹងអត់មានកន្លែងគេសម្លាប់ទេ នៅជិតៗភូមិយើងហ្នឹង?

ជួប :	សម្លាប់ខ្វះអី គេបិទមុខជិតៗ ។

ដានី :	ចុះកាលទោលើកទំនប់អាងត្រពាំងថ្មអីពួទៅដែល?

ជួប ៖ អត់ដែលបានទៅទេ ។

ដានី ៖ អត់ដែលបានទៅទេ?

ជួប ៖ ទៅតែប្អូន ។

ដានី ៖ ទៅតែប្អូនទេណ៎ុះ?

ជួប ៖ បាទ!

ដានី ៖ ពូនៅតែក្នុងភូមិទេអញ្ចឹង?

ជួប ៖ បើប្រពន្ធខ្ញុំទៅ ។

ដានី ៖ អញ្ចឹងពួកខាងនិរតីម៉ោ អត់ត្រូវជាមួយយើងទេ?

ជួប ៖ ទេមិនមែនត្រូវអី យើងខ្លាចវាហ្នឹង វាថាត្រង់ណាក៏បានដែរ ។

ដានី ៖ ថាណាក៏បានដែរ?

ជួប ៖ ហ្នឹងហើយ សុទ្ធតែនៅក្រោមកណ្តាប់ដៃវា ។

ដានី ៖ ហ៊ី! នៅក្រោមកណ្តាប់ដៃ?

ជួប ៖ បាទ! វាទៅនៅនោះ ដូចថាទៅនៅក្នុងគុកអញ្ចឹង អាគុកអត់ជញ្ជាំងខាំងដែរហ្នឹង ។

ដានី ៖ បាទ! ពួកអ្នកនិរតីម៉ោច្រើនដែរអញ្ចឹង?

ជួប ៖ ហ៊ី! ម៉ោមាក្រុមវាទាំងអស់ តាំងពីស្រុកពីអីហ្នឹង ស្រុកអីសុទ្ធតែពួកនិរតី ។

ដានី ៖ បាទ!

ជួប ៖ ចៅហ្វាយស្រុក ចៅហ្វាយខេត្ត ។

ដានី ៖ អ្ហូ! ម៉ោមួយក្រុមម៉ង់?

ជួប ៖ នោះហើយ ម៉ោដល់សាខាភូមិអីសុទ្ធតែវានោះម៉ង់ ។

ដានី ៖ បាទ! មានស្រីមានប្រុសអញ្ចឹងទៅ?

ជួប ៖ មានស្រី មានប្រុសអញ្ចឹងហើយ ។

ដានី ៖ ក្មេងៗឬក៏ចាស់ៗ?

ជួប ៖ ចាស់ខ្លះ ក្មេងខ្លះ ។

ដានី ៖ ចុះដល់ពេលបែកយួនចូលហ្នឹង ពួកហ្នឹងរត់ទៅណាទៅ?

ជួប ៖ មិនដឹងរត់ទៅណាទៅណីទេ រត់ពេញភូមិ ។

ជិតខាង ៖ គេចាប់បានសម្លាប់តាមវាលតាមកាលខ្លះ ។

ដានី ៖ អញ្ចឹងពូរត់ទៅស្វាយហើយ ត្រឡប់មកវិញ ម៉ោនៅហ្នឹងហើយយ៉ាងម៉េចទៀតទៅ?

ជួប ៖ នៅស្វាយចេក ។

ដានី ៖ នៅស្វាយចេក?

ជួប ៖ បាទ!

ដានី ៖ នៅរហូតដល់ពេលណាទៅ បានត្រឡប់មកវិញ?

ជួប ៖ នៅបាត់ប្រពន្ធបាត់កូនទាំង៤ ។

ដានី ៖ ឆ្នាំណាបានពូម៉ោដល់នេះ?

ជួប ៖ អាឆ្នាំ ប៉ុន្មានទេ សម័យគ្រាប់ផ្លោងច្រើនណាស់កាលហ្នឹង ។

ដានី ៖ សម័យគ្រាប់ផ្លោងច្រើន?

ជួប ៖ ហ្នឹងហើយ ឯនេះគឺប៉ារ៉ាវរំដោះបានច្រើនហើយ ។

ដានី ៖ បាទៗ!

ជួប ៖ ខ្ញុំស៊ូនៅឯស្វាយចេកមិនបាន ក៏ត្រឡប់មកនេះវិញ ។

ដានី ៖ បាទៗ!

ជួប ៖ នៅនោះគេបាញ់គ្នារាល់ថ្ងៃហ្នឹង ។

ដានី ៖ អ្ហូ!

ជួប ៖ ចុះម៉ែឪនៅនេះ ។

ដានី ៖ ចុះពូអត់ដែលមានធ្វើកងទ័ពអីនឹងគេទេ?

ជួប ៖ ទេ!អត់ដែលធ្វើទេ ។

ដានី ៖ ធ្វើប្រជាជនរហូត?

ជួប ៖ ធ្វើខ្លះដែរ ។

ដានី ៖ ធ្វើអីគេ?

ជួប ៖ ធ្វើនៅស្វាយចេក មុនដំបូងធ្វើប្រធានយុវជនមាឃុំស្វាយចេក ។

ដានី ៖ ធ្វើប្រធានយុវជន?

ជួប ៖ ហ្នឹងហើយ កាលនោះយួនរំដោះបានគេឲ្យធ្វើទៅប្រធានយុវជនទៅ ។

ដានី ៖ អ្ហូ!ធ្វើប្រធានយុវជន?

ជួប ៖ ហ្នឹងហើយ ធ្វើប្រធានយុវជន ។

ដានី ៖ ធ្វើដល់ពេលណា?

ជួប ៖ ធ្វើមករើសធារូដើររើសកាលហ្នឹង ។

ដានី : អ៊ូ! ហើយម៉េចទៀតទៅ?

ដួប : ទាហានដែលខ្ញុំរើសបាននៅតូចៗហ្នឹងសព្វថ្ងៃ អាណាដែលនៅរស់ ។

ដានី : ចុះពូអត់ធ្វើទេ ខ្លួនឯង?

ដួប : អត់ធ្វើទេ ។

ដានី : បាទ! ហើយដល់ពេលក្រោយម៉ោម៉េចទៀតបានផ្លាស់ពីស្វាយចេក មកនៅថ្មពួកវិញ អ៊ូ ម៉ោបន្ទាយឆ្មារនឹងវិញ?

ដួប : ម៉ោនេះដឹងថាស្រុកស្រួលហើយ វានៅនោះវាយ៉ាប់ពេក ។

ដានី : យ៉ាប់ម៉េច?

ដួប : យ៉ាប់វានេះហ្នឹង គ្រាប់ផ្លោងវាបាញ់ត្រឹងៗៗៗមិនទាន់វើបែកនោះៗ បាញ់រាល់ថ្ងៃ ចូល ។

ដានី : អ៊ូ! ក៏ម៉ោនេះម៉ោ?

ដួប : ហ្នឹងហើយ ។

ដានី : អញ្ចឹងឈប់ធ្វើប្រធានយុវជន?

ដួប : ឈប់ហើយ បាញ់គ្នារយ៉ាវយ៉ៃក៏ឈប់ ។

ដានី : អញ្ចឹងធ្វើបានប៉ុន្មានឆ្នាំប្រធានយុវជន?

ដួប : ធ្វើបាន១ឆ្នាំ ។

ដានី : ១ឆ្នាំ?

ដួប : ធ្វើបាន១ឆ្នាំ ។

ដានី : ម៉េចបានឈប់?

ដួប : បាញ់គ្នាគេឲ្យឈប់ ។

ដានី : គេឲ្យឈប់?

ដួប : បាទ!

ដានី : អ៊ូ!

ដួប : គេរើសប្រធានយុវជនថ្មីទៀត ។

ដានី : អ៊ូ! គេរើសប្រធានយុវជនថ្មី អញ្ចឹងពូឈប់ធ្វើរហូតម៉ោ?

ដួប : ឈប់ធ្វើរហូត ធ្វើប្រធានក្រុមទៀត ។

ដានី : ធ្វើប្រធានក្រុម?

ជួប ៖ ហ្នឹងហើយ ។

ដានី ៖ ប្រធានក្រុមនៅណា?

ជួប ៖ នៅស្វាយចេកនោះហើយ ។

ដានី ៖ អ្ហូ! ធ្វើប្រធានក្រុមរហូតដល់ពេលពូម៉ោនៅនេះ?

ជួប ៖ ហ្នឹងហើយដល់បែកបាក់គ្នា ដល់សព្វថ្ងៃនេះប្រធានក្រុមហ្នឹងឡើងធ្វើប្រធានឃុំ ប្រធានភូមិបាត់អស់ហើយ ។

ដានី ៖ បាទ!ចុះពុម៉ោនេះមានធ្វើអីទៀតឬអត់?

ជួប ៖ ទេ!អត់មានធ្វើអីទេ សព្វថ្ងៃហ្នឹងធ្វើការនៅប្រាសាទ ។

ដានី ៖ បាទ!?

ជួប ៖ ធ្វើការនៅក្នុងប្រាសាទ ។

ដានី ៖ ធ្វើការក្នុងប្រាសាទ?

ជួប ៖ បាទ!

ដានី ៖ អ្ហូ!ធ្វើការខាងអីអាហ្នឹង ធ្វើខាងអង្គការឬក៏ខាងរដ្ឋាភិបាល?

ជួប ៖ ធ្វើខាងរដ្ឋាភិបាល ធ្វើឆ្មាំម ។

ដានី ៖ ធ្វើឆ្មាំម?

ជួប ៖ បាទ!

ដានី ៖ ចាប់ធ្វើតាំងពីអង្កាល់ម៉ោ?

ជួប ៖ ធ្វើបានប៉ុន្មាន ប្រហែល២ឆ្នាំហើយដឹង ។

ដានី ៖ ២ឆ្នាំហើយ?

ជួប ៖ បាទ!

ដានី ៖ ធ្វើប្រាសាទផង ធ្វើស្រែផង?

ជួប ៖ បាទ!ធ្វើស្រែផង ប៉ុន្តែម៉ាអាទិត្យគេឲ្យធ្វើ២ថ្ងៃ ដើរយាមល្បាតគេហ្នឹង ។

ដានី ៖ បាទ!

ជួប ៖ ដល់យើងទំនេរពីស្រែពីអីនេះ គេឲ្យធ្វើច្រើនថ្ងៃ ។

ដានី ៖ បាទៗ!ចុះពូសព្វថ្ងៃពូដែលឮពត៌មានស្ដីតុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមជាពិសេសថ្មីៗនេះសវនាការកាត់ក្ដីឌុច?

ជួប ៖ ធ្លាប់ឮដែរ តែចាំមិនបាន ។

ដានី ៖ អ្ហូ!ពូដែរ តែចាំមិនបាន?

ជួប ៖ ចាំមិនបាន ។

ដានី ៖ ថ្មីៗនេះតុលាការបានកាត់ក្ដីពីការកាត់ទោសឌុចឲ្យជាប់គុក៣៥ឆ្នាំ ហើយក្រោយម៉ោ ដោយសារមានការបន្ធូរបន្ថយឃុំខ្លួនឌុចឆ្នាំ៩៩ ដល់២០០០នេះ១១ឆ្នាំ ហើយនឹង ដោយសារការចាប់ខ្លួនដឹបូងគេមានខុសនីតិវិធីនេះ គេលើកទោសអស់៥ឆ្នាំ អញ្ចឹង ឥឡូវនៅសល់តែ១៩ឆ្នាំ ពូយល់ឃើញម៉េចដែរតុលាការដែលគេកាត់ទោសឌុច ឲ្យ ជាប់គុក១៩ឆ្នាំហ្នឹង?

ជួប ៖ មិនដឹងយ៉ាងណាទេ ។

ដានី ៖ អត់ដឹងទេ?

ជួប ៖ បាទ!ស្រេចតែគេទៅ ស្ដាប់ដែរតែមិនសំខាន់ មិនសូវយកចិត្តទុកដាក់ផង ។

ដានី ៖ បាទ!ដូចឆ្នាំក្រោយនេះគេចាប់ផ្ដើមកាត់ទោសមេដឹកនាំជាន់ខ្ពស់ដូចជា អៀង សារី នួន ជា អៀងធីរិទ្ធ ហើយនឹងខៀវ សំផនទៀត ពូយល់ឃើញថាតុលាការដែលគេបង្កើត ឡើងដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ ហើយនឹងជនទាំងឡាយណាដែលទទួលខុសត្រូវ ខ្ពស់បំផុតចំពោះឧក្រិដ្ឋដែលកើតមានឡើងក្នុងសម័យខ្មែរក្រហមពី៧៥ដល់ឆ្នាំ៧៩ហ្នឹង ពូយល់ថាត្រឹមត្រូវដែរឬមិនត្រឹមត្រូវទេ សម្រាប់ពូ?

ជួប ៖ ខ្ញុំថាត្រឹមត្រូវរបស់គេហើយ ។

ដានី ៖ ត្រឹមត្រូវ?

ជួប ៖ ហ្នឹងហើយ ។

ដានី ៖ ម៉េចបានពូគិតថាត្រឹមត្រូវ?

ជួប ៖ ដូចជាវារស់មិនយូរទេ ពួកហ្នឹងរស់មិនបានយូរឡើយ ស្លាប់បាត់ទៀតឥឡូវហ្នឹង ហើយ ។

ដានី ៖ វាម៉េច?

ជួប ៖ វារស់អត់បានយូរឡើយ ចុះអាខ្លះអាយុជិត៨០-៦០ហើយ ។

ដានី ៖ បាទ!ដូចថាគាត់ចាស់ជិត៨០-៦០ហើយ ម៉េចចាំបាច់កាត់ទោសគាត់ធ្វើអី?

ជួប ៖ និយាយតែរឿងច្បាប់គេត្រូវតែកាត់ទោស ព្រោះជាទោសឧក្រិដ្ឋ ។

ដានី ៖ បាទៗ!អញ្ចឹងពូខ្ញុំដូចជាអត់មានសំនួរអីចង់សួរនាំពូទៀតហើយ ពូមានអីចង់បន្ថែមនូវ អាអីដែលខ្ញុំអត់ទាន់បានសួរនាំពូទៀតទេ?

ជួប ៖ អត់ទេខ្ញុំ ។

ដានី ៖ បាទ! អញ្ជើញខ្ញុំអរគុណពូច្រើនៗ

**ចប់**